# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2011, 13:34
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំធ្វើការបញ្ជាក់លើសំណើរបស់ អៀង សារី សុំឲ្យពន្លឿនការធ្វើសេចក្តីសម្រេចលើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងនៅកិច្ចប្រជុំរៀបចំសវនាការ

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") តទៅនេះសូមដាក់សំណើសុំការបញ្ជាក់អំពីពេលវេលាដែលបានស្នើសុំសម្រាប់ការធ្វើសេចក្ដីថ្លែងបើកក្នុងរឿងក្ដីរបស់គាត់ ដែលបានកត់សម្គាល់ក្នុងសំណើរបស់គាត់សុំឲ្យមានការសម្រេចជាបន្ទាន់លើបញ្ហាជាក់លាក់មួយចំនួន ដែលបានលើកឡើងនៅកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១[1] ។ សំណើសុំការបញ្ជាក់នេះ ត្រូវបានធ្វើឡើងជាចាំបាច់ស្របតាមចម្លើយតបរបស់ កសព ទៅកាន់សំណើនេះ[2] ។ វាហាក់បីដូចជាថា កសព បានយល់ខុស ឬបានបកស្រាយខុសនូវគោលជំហរដែលបានលើកឡើងដោយមេធាវីការពារក្ដី ។

១. តាងនាមឲ្យលោក អៀង សារី មេធាវីការពារក្ដីសូមស្នើរយៈពេលសរុបចំនួន១០ម៉ោង សម្រាប់ការធ្វើសេចក្ដីថ្លែងបើករបស់ខ្លួន ។ ការយោងណាមួយទៅលើរយៈពេល២ម៉ោងដែលបានផ្ដល់ឲ្យភាគីក្នុងរឿងក្ដី ឌុច គឺគ្រាន់តែសម្រាប់គោលបំណងបង្ហាញ និងប្រៀបធៀបតែប៉ុណ្ណោះ ។ មេធាវីការពារក្ដីមិនដែលលើកឡើងថា ខ្លួន និងភាគីដទៃទៀតរួមទាំងក៏ កសព ផងដែរ ត្រូវតែមានរយៈពេលកំណត់២ម៉ោង ដើម្បីធ្វើសេចក្ដីថ្លែងបើករបស់ពួកគេរៀងៗខ្លួននោះទេ ។

២. មេធាវីការពារក្ដីលោក អៀង សារី មិនមានបំណងនិយាយ ឬធ្វើសកម្មភាពក្នុងនាមឲ្យជនជាប់ចោទដទៃទៀតឡើយ ។ ចំណុចនេះគឺបានបញ្ជាក់យ៉ាងច្បាស់ក្នុងប្រយោគផ្ដើមនៃសារណានីមួយៗ ដែលបានដាក់តាងនាមឲ្យលោក អៀង សារី ។ ជនសង្ស័យទាំងបួននាក់ក្នុងករណីនេះមិនបានធ្វើសកម្មភាពជាក្រុមតែមួយឡើយ ហើយក៏មិនត្រូវចាត់ទុកថាជាក្រុមតែមួយដែរ ។ ដូច្នេះ នៅពេលដែលក្រុមមេធាវីការពារក្ដីលោក អៀង សារី ស្នើសុំរយៈពេលសរុបចំនួន១០ម៉ោងសម្រាប់ការធ្វើសេចក្ដីថ្លែងបើករបស់ "មេធាវីការពារក្ដី" វាច្បាស់ណាស់ថាការស្នើសុំនេះ គឺសម្រាប់តែការថ្លែងបើករបស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី តែប៉ុណ្ណោះ។ ចំពោះជនជាប់ចោទដទៃទៀតទុកឲ្យមេធាវីការពារក្ដីរបស់ពួកគេស្នើសុំចំនួនពេលវេលាដែលពួកគេយល់ឃើញថាមានការចាំបាច់សម្រាប់សេចក្ដីថ្លែងបើករបស់ពួកគេ ។

៣. មេធាវីការពារក្ដីកត់សម្គាល់ឃើញថាក្នុងករណី ឌុច កសព ទទួលបានការបែងចែកពេលវេលា

---

[1] សំណើរបស់លោក អៀង សារី សុំឲ្យមានការសម្រេចជាបន្ទាន់លើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងនៅកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ឯកសារ E87។

[2] ចម្លើយតបរបស់ កសព ទៅកាន់ "សំណើរបស់លោក អៀង សារី សុំឲ្យមានមានការសម្រេចជាបន្ទាន់លើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងនៅកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១", ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១, ឯកសារ E87/1។ ។

សម្រាប់ការធ្វើសេចក្ដីថ្លែងបើករបស់ខ្លួន ស្មើគ្នានឹងក្រុមមេធាវីការពារក្ដី ខុច ដែរ។ មេធាវីការពារក្ដីសូមផ្ដល់អនុសាសន៍ថា កសព គួរតែទទួលបានការបែងចែកពេលវេលាស្មើគ្នានឹងចំនួនពេលវេលាដែលមេធាវីការពារក្ដីបានស្នើសុំដែរ ។ ឧទាហរណ៍ រយៈពេល១០ម៉ោង ។ ពិតណាស់ ដោយសារតែករណីនេះក្រៅពីលោក អៀង សារី មានជនជាប់ចោទបីនាក់ផ្សេងទៀត កសព អាចទទួលបានការបែងចែកពេលវេលាលើសពី១០ម៉ោង ដែលបានស្នើឡើងដោយមេធាវីការពារក្ដី ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្ដីគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្ដម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី